# ព្រះរាជក្រមលេខ ១១ ន.ស ៩៤ស្តីពីច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី ២៤.៩.១៩៩៣ បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១.១១.១៩៩៣ គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសអោយប្រើ

ច្បាប់ដែលអនុម័តដោយរដ្ឋសភានាថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដូចមានសេចក្តីតទៅនេះ :

# ច្បាប់
# ស្ដីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ១៩៩៥

# ភាគទី ១
# ការរៀបចំច្បាប់ហិរញ្ញវត្ថុ

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១-**

ត្រូវបានអនុញ្ញាតក្នុងឆ្នាំ ១៩៩៥ ឲ្យប្រមូលចូលថវិកាទូទៅរបស់រដ្ឋនូវ ពន្ធដារ វិភាគទានអាករ ផលទុន និងចំណូលនានា រួមទាំងការសម្រេចឲ្យចំណាយមូលនិធិ បដិភាគ និងធនធានបានមកពីការខ្ចីបុល ដែលបានគ្រោងទុកនៅតារាង " ក " ក្នុងភាគទី២ នៃច្បាប់នេះ ក្នុងចំនួនទឹកប្រាក់សរុប ១.០៥៨.៦០០ លានរៀល ដែលត្រូវបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ ៥៨១.១០០ លានរៀល
- ចំណូលជាមូលធន ៤៧៧.៥០០ លានរៀល

**មាត្រា ២-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយក្នុងថវិការទូទៅរបស់រដ្ឋសម្រាប់ឆ្នាំ ១៩៩៥ ត្រូវបានកំណត់ស្មើនឹង ១.០៥៨.៦០០ លានរៀល និងត្រូវបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ ៦៥២.៧០០ លានរៀល
- ចំណាយជាមូលធន ៤០៥.៩០០ លានរៀល

**មាត្រា ៣-**

ហាមប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែ ក៏ដូចជាអាណាប័កដែលបានទទួលការប្រគល់សិទ្ធិក្នុងការរិះរកនូវវិធានការទាំងឡាយណា ដែលនាំឲ្យបង្កើនចំណាយ ដែលអាចកត់ត្រាទៅក្នុងឥណទានថវិកាទូទៅរបស់រដ្ឋ ហើយដែលពុំមែន

បានកើតចេញមកពីការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុឬពីការអនុវត្តច្បាប់ក្រឹត្យនិងបទបញ្ជាដែលមានពីមុនកិច្ចសន្យាឲ្យចំណាយនោះទេ។ប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែក៏ដូចជាអាណាប័កដែលបានប្រគល់សិទ្ធិត្រូវទទួលខុសត្រូវដោយផ្ទាល់ខ្លួនចំពោះការសន្យាចំណាយទាំងឡាយណាដែលផ្ទុយនឹងបទបញ្ញត្តិខាងលើនេះ ។

មាត្រា ៤-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយជាប្រចាំរបស់រដ្ឋនៅឆ្នាំ១៩៩៥ត្រូវបានកំណត់ស្មើនិង ៦៥២.៧០០ លានរៀល ។ ឥណទាននេះត្រូវធ្វើការបែងចែកទៅតាមក្រសួងនីមួយៗនិងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗនិងទៅតាមប្រភេទដូចមានចែងក្នុងតារាង" ខ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

មាត្រា ៥-

ត្រូវបានពន្យារជាបណ្តោះអាសន្ននូវការអនុវត្តន៍ខុសគ្នានៃឥណទានកម្មវិធីឥណទានសន្យាចំណាយ និង ឥណទានទូទាត់ សម្រាប់ចំណាយជាមូលធននៃថវិការដ្ឋដូចមានចែងនៅក្នុងតារាង" គ" នៃច្បាប់ហិរញ្ញវត្ថុនិងដែលបានចែងក្នុងមាត្រា ២០ និងមាត្រា ២១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

មាត្រា ៦-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយជាមូលធននៃថវិការដ្ឋសម្រាប់ឆ្នាំ ១៩៩៥ ត្រូវបានកំណត់ ៤០៥.៩០០ លានរៀល ។
ឥណទានទាំងអស់នេះត្រូវបានបែងចែកទៅតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកានីមួយៗ ដូចមានចែងក្នុងតារាង" ឃ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

មាត្រា ៧-

ចំនួនក្របខ័ណ្ឌមន្ត្រីរាជការរបស់រដ្ឋបាលស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាក្រសួង ខេត្ត ក្រុង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនានា ត្រូវបានកំណត់សម្រាប់ឆ្នាំ ១៩៩៥ ស្មើនិង ១៤៣.៤៥៥ កន្លែង

## ជំពូកទី ២
## បទបញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

មាត្រា ៨-

បទបញ្ញត្តិនៃមាត្រា ១៥.៤០ និង ៤១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ខែធ្នូឆ្នាំ១៩៩៣ត្រូវទុកជានិរាករណ៍ហើយត្រូវបានជំនួសដោយបទបញ្ញត្តិដូចតទៅ៖

មាត្រា ១៥ ថ្មី- ចំណាយជាមូលធននៃថវិកា សម្រាប់ការអនុវត្តន៍កម្មវិធីការអនុវត្តន៍គំរោងវិនិយោគ និងសម្រាប់អន្តរាគមន៍ជាមូលធនរបស់រដ្ឋក្នុងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធសហគ្រាសសាធារណៈឬតាមមធ្យោបាយចូលរួមភាគហ៊ុន ព្រមទាំងការទូទាត់បំណុល ។ ចំណាយជាមូលធន បង្កើតចេញជាប្រភេទទី ៥ នៃថវិកា ។ ចំណាយនេះត្រូវបានចាត់ថ្នាក់ទៅតាមប្រភពហិរញ្ញប្បទាន ជាជំពូកថវិកា ដែលមានជាបន្តបន្ទាប់ដូចតទៅ ៖

- វិនិយោគដោយ ហិរញ្ញប្បទានក្នុងប្រទេស
- វិនិយោគដោយ ហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់
- កិច្ចប្រតិបត្តិការ ហិរញ្ញវត្ថុ
- ការទូទាត់ប្រាក់ខ្ចីបុល

វិនិយោគដោយ ហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់បង្កើតបានជា" ជំនួយគំរោងការ " ក្នុងនោះអ្នកផ្តល់មូលនិធិធ្វើហិរញ្ញប្បទានផ្ទាល់ ខាងវិនិយោគសាធារណៈដោយចំណូលនៃជំនួយទាំងនោះឥតឆ្លងកាត់ តាមរតនាគារឡើយ។

ឥណទានកត់ត្រាក្នុងថវិកាប្រភេទនេះ ពុំអាចប្រើប្រាស់ផ្ទាល់បានដោយអាណាប័កឡើយ។ឥណទាននេះមានលក្ខណៈប៉ាន់ស្មានហើយ ពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពណាមួយទៅជំពូកថវិកាផ្សេងៗ ទៀតបានឡើយ ។ ឥណទាននេះទុកសម្រាប់ឆ្លុះបញ្ចាំងក្នុងគណនីសាធារណៈក្នុងលក្ខណៈនៃនិយ័តភាព វិនិយោគដែលត្រូវអនុវត្តដោយអ្នកផ្តល់ ។

មាត្រា ៩០ ថ្មី- ការផ្ទេរឥណទានពីក្រសួងមួយ ឬពីស្ថាប័នសាធារណៈថ្នាក់ប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវបានសម្រេចដោយច្បាប់ស្តីពីហិរញ្ញវត្ថុកែតម្រូវ ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ឬ ពីស្ថាប័នសាធារណៈ ថ្នាក់ប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាលអាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីនៃការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយនិងការបែងចែកឥណទានតាមជំពូកនីមួយៗទេ។

មាត្រា ៩១ -ថ្មី ការបង្វែរឥណទានពីជំពូកមួយ ទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួងមួយឬ ស្ថាប័នសាធារណៈ ថ្នាក់ប្រហាក់ប្រហែលមួយ ឬផ្នែកមួយទៅផ្នែកមួយទៀតនៅក្នុងរង្វង់របស់ក្រសួងមួយ ឬ ស្ថាប័នសាធារណៈថ្នាក់ប្រហាក់ប្រហែលណាមួយត្រូវធ្វើឡើង ដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែពីឥណទាន ជាមូលធនសម្រាប់ (វិនិយោគ )ទៅជាឥណទានចំណាយជាប្រចាំ (សម្រាប់ដំណើរការ ) ។

## ជំពូកទី ៣

## បទបញ្ញត្តិនាំខឡាយស្តីពីពន្ធ និងអាករដែលប្រមូលដោយអគ្គការពន្ធ

## ផ្នែកទី ១

## បទបញ្ញត្តិស្តីពីសារពើពន្ធ

## I - ពន្ធលើប្រាក់បៀវត្ស

មាត្រា ៩-

ត្រូវបានបង្កើតពន្ធលើប្រាក់បៀវត្ស ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

មាត្រា ១០-

ពន្ធលើប្រាក់បៀវត្សគឺជាពន្ធប្រចាំខែ ដែលកំណត់លើប្រាក់ចំណូលសរុប ទោះជាមានឈ្មោះ ហៅថាជាអ្វីក៏ដោយហើយនិង លើអត្ថប្រយោជន៍ជាវត្ថុដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាព បំរើសហគ្រាសសាធារណៈ ឬ ឯកជន ។

មាត្រា ១១-

លើកលែងតែមានបទបញ្ញត្តិដោយឡែកជាទ្វេភាគី ឬពហុភាគី និងជាពិសេសអនុសញ្ញាសារពើពន្ធអន្តរជាតិពន្ធនេះអាចទារបាន :

* កាលបើសកម្មភាពបំរើការងារ បានប្រព្រឹត្តនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជានិយោជិក ឬអ្នកបាន ទទួលបៀវត្សបានតាំង ឬមិនបានតាំង ទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្តីនិង ទោះបីជាទឹកប្រាក់ ដែលបានទទួលនោះមានដើមកំណើតពីទីណាក្តី ដោយរាប់បញ្ចូលក្នុងនេះ ទាំងអ្នកបានទទួល ដែលបំពេញសកម្មភាពក្នុងក្របខ័ណ្ឌ នៃគម្រោងហិរញ្ញប្បទានក្រៅប្រទេសផង ។

* កាលបើសកម្មភាពបំរើការងារ បានប្រព្រឹត្តនៅខាងក្រៅ ព្រះរាជាណាចក្រកម្ពុជាហើយនិយោជិកមានទីលំនៅនៅកម្ពុជា ។ គ្មានករណីណាមួយត្រូវបានឲ្យរួចពន្ធបៀវត្សដែលទទួលបានក្នុងក្របខ័ណ្ឌនៃការងារទទួលតពីអ្នកដទៃឡើយ ។

មាត្រា ១២-

ត្រូវបានលើកលែងពន្ធ :

* ប្រាក់សងដោយពិតប្រាដកនូវចំណាយខាងវិជ្ជាជីវៈដែលបានចាយដោយអ្នកបំរើការងារតាមសេចក្តីបង្គាប់ និង សម្រាប់ជាប្រយោជន៍នៃនិយោជកហើយដែលបានបំពេញលក្ខខ័ណ្ឌ ៣ ដូចតទៅ ៖

១- បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស

២- មិនបង្ហាញលក្ខណៈហួសប្រមាណឬស្តុកស្តម្ភហួសហេតុ

៣-បានបង្ហាញជាភស្តុតាងដោយវិក្កយប័ត្រវាយលំអិត និងបានទូទាត់ស្រេចបាច់ហើយដែលបានធ្វើក្នុងនាម អ្នកបានទួលប្រាក់សំណងនូវចំណាយពិតប្រាដក

* ប្រាក់បំណាច់នៃការបញ្ឈប់លែងឲ្យធ្វើការក្នុងកម្រិតដែលបានបញ្ញត្តិទុកក្នុងច្បាប់ការងារ

* លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច

* ការផ្គត់ផ្គង់ឲ្យដោយឥតយកថ្លៃឬយកថ្លៃទាបជាងថ្លៃដើម នូវឯកសណ្ឋាន ឬ បរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស

*ប្រាក់បំណាច់ម៉ោការ សម្រាប់ចំណាយបេសកម្ម និង ការធ្វើដំណើរ ។

ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់សំណងពិតប្រាកដនូវចំណាយ ដូចបានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ។

មាត្រា ១៣-

ពន្ធនេះត្រូវជំពាក់ដោយ អ្នកបានទទួលចំណូល ដែលត្រូវជាប់ពន្ធដោយរាប់បញ្ចូលក្នុងនេះទាំងអានិកជនបរទេសផង លើកលែងតែមានបញ្ញត្តិ ដោយឡែកផ្ទុយដែលបានកំណត់ក្នុង អនុសញ្ញាអន្តរជាតិ ឬ ច្បាប់ស្តីពីវិនិយោគទុន ។

បើនិយោជកនៅបរទេសគឺ អ្នកតំណាងសារពើពន្ធ ដែលបានចាត់តាំងនៅកម្ពុជាដោយនិយោជកនោះ ជាអ្នកបំពេញភារកិច្ចកាត់ទុកពន្ធលើបៀវត្ស មុននឹងបើកបៀវត្សឲ្យ អ្នកបម្រើការងារនិងជា អ្នកទទួលបំពេញកិច្ចការបង្វែរប្រាក់ពន្ធជូនរដ្ឋ ។

មាត្រា ១៤-

មូលដ្ឋានសម្រាប់គិតពន្ធប្រចាំខែ រួមមានលាភការ សរុបបូកបន្ថែមអត្ថប្រយោជន៍ ជាវត្ថុវាយតម្លៃតាមតម្លៃពិតប្រាកដនិងដកចេញនូវ ៖

១- ប្រាក់កាត់ទុកជាកាតព្វកិច្ចដែលប្រតិបត្តិតាមច្បាប់សង្គមកិច្ចដើម្បីបង្កើតសោធននិវត្តន៍និងការគាំពារសង្គមកិច្ច

២- ប្រភេទនៃលាភការ ដែលបានឲ្យរួចពន្ធតាមមាត្រា ១២ ខាងលើ ។

មាត្រា ១៥-

លាភការសរុបរួមមាន លាភការសុទ្ធសាធបូកបន្ថែមនូវប្រាក់កំរៃនានា ប្រាក់បំណាច់ ប្រាក់ម៉ោងធ្វើការបន្ថែម និងប្រាក់បំណាច់បន្ទាប់បន្សំផ្សេងៗទៀត គ្រប់ប្រភេទដូចជា ៖

១- ប្រាក់ដែលបានបើកទៅ ឲ្យបរទេសដោយនិយោជក និងដែលផ្តល់គុណប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលឲ្យដល់អ្នកបម្រើការងារ

២-ប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចី ឬប្រាក់រំដោះដែលបានបើកឲ្យដោយនិយោជកឲ្យដល់អ្នកបម្រើការងារប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចីឬប្រាក់រំដោះត្រូវបូកបន្ថែមលើលាភការដែលត្រូវជាប់ពន្ធ ក្នុងខែដែលប្រាក់ទាំងនោះបានបើក ។ ត្រូវបានកាត់បន្ថយពីលាភការនៃខែ នូវប្រាក់ដែលអ្នកបម្រើការងារបានបង់សងទៅវិញ ។

មាត្រា ១៦-

១- ពន្ធត្រូវបាន់កំណត់ដោយគិតយកលើលាភការប្រចាំខែ ដែលត្រូវជាប់ពន្ធ និងត្រូវគិតជាលេខមូលដោយយកត្រឹមតែខ្ទង់ខាងក្រោមតាមអត្រាកំណើននៃតារាងអត្រាពន្ធប្រចាំខែដូចតទៅ ៖

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី ១ រ ០០ ដល់ ៧៥០.០០០ រ ០០ | ០% |
| ពី ៧៥០.០០១ រ ០០ ដល់ ១.០០០.០០០ រ ០០ | ៥% |
| ពី ១.០០០.០០១ រ ០០ ដល់ ១០.០០០.០០០ រ ០០ | ១០% |
| ពី ១០.០០០.០០១ រ ០០ ដល់ ២០.០០០.០០០ រ ០០ | ១៥% |
| លើសពី ២០.០០០.០០០ រ ០០ | ២០% |

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ អ្នកបម្រើការងារជាសហព័ទ្ធណាមួយដែលមានកូនជាអនីតិជនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០ រៀល ក្នុងកូនម្នាក់ៗ ។

២-ករណីគ្មានកិច្ចព្រមព្រៀង អន្តរជាតិរវាងរដ្ឋនានាជនជាតិខ្មែរ និងនិវាសជនបរទេសទាំងឡាយ ដែលបានទទួលនៅក្រៅកម្ពុជានូវបៀវត្ស ដែលបានបង់ពន្ធតាមបទបញ្ញត្តិ នៃច្បាប់បរទេស ត្រូវបានទទួលនូវ ឥណទានពន្ធ

មួយដែលត្រូវដកចេញពីពន្ធលើប្រៀវត្សដែលត្រូវបង់នៅកម្ពុជា ក្នុងលក្ខខ័ណ្ឌ ដែលមាន ការបង្ហាញភស្តុតាងបញ្ជាក់អំពីការបង់នេះនៅបរទេស ។

២.១- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅកម្ពុជាមុនពេលដកឥណទានពន្ធ នេះត្រូវយកប្រៀវត្សដែលបានទទួលនៅកម្ពុជានិងនៅបរទេសមកគិត ។

២.២- ឥណទានពន្ធដែលត្រូវដកចេញ ត្រូវបានកំណត់ដោយយកតារាងអត្រាពន្ធប្រចាំខែដូចបានចែងក្នុង វាក្យខ័ណ្ឌទី១មកគិតលើប្រៀវត្សដែលបាន ទទួលនៅបរទេស ។

២.៣- ផ្ទុយពីគោលការណ៍ទូទៅការគិតគូរ និងការបង់ប្រាក់ពន្ធត្រូវធ្វើ ក្នុង កំលុងឆ្នាំ បរវេណីដែលបន្ទាប់ពីឆ្នាំដែលប្រៀវត្ស បរទេសត្រូវបានទទួល។

២.៤- និយោជកនៅកម្ពុជា និងអ្នកបម្រើការងារត្រូវទទួលខុសត្រូវរួមគ្នា ក្នុង ការបង់ពន្ធលើប្រៀវត្សដែលត្រូវបង់នៅកម្ពុជា ។

មាត្រា ១៧-

ប្រៀវត្សដែលមានចំនួនពាក់ព័ន្ធនឹងកាលវេលាក្រោម ឬលើសពីមួយខែ ត្រូវបំបែកឲ្យទៅជាខែដើម្បីអនុវត្តតារាងអត្រាពន្ធប្រចាំខែ ។

មាត្រា ១៨-

ការបើកប្រៀវត្ស បង្កើតជាហេតុបណ្តាលឲ្យជាប់ពន្ធ ។

មាត្រា ១៩-

ពន្ធត្រូវប្រមូលជាប្រយោជន៍រតនាគារជាតិតាមរបៀបកាត់ទុកជាមុនរៀងរាល់ខែដោយនិយោជកក្នុងពេលបើកប្រៀវត្សម្តងៗ ។

មាត្រា ២០-

ការកាត់ទុកប្រាក់ពន្ធដែលទាក់ទងដល់ការបើកប្រាក់ ធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ ជូនទៅអង្គការពន្ធដារនៅទីកន្លែង នៃលំនៅដ្ឋានឬគ្រឹះស្ថានចម្បងនៃបុគ្គលដែលបំពេញកិច្ចការកាត់ទុកប្រាក់ពន្ធនេះ ។

មាត្រា ២១-

គ្រប់និយោជកជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបើកប្រាក់ ត្រូវជាប់ពន្ធត្រូវទទួលបំពេញកិច្ចការកាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស ។

និយោជកត្រូវកាន់បញ្ជីការប្រចាំខែ ដែលចុះចំនួនទឹកប្រាក់បានបើក និងបានកាត់ទុកហើយដោយ ត្រូវបញ្ជាក់សម្រាប់អ្នកទទួលប្រាក់ម្នាក់ៗនូវ ៖

- នាម និងគោត្តនាម
- ភេទ
- ថ្ងៃ ខែ ឆ្នាំកំណើត
- លំនៅដ្ឋាន
- ប្រភេទការងារ
- ថ្ងៃចូលធ្វើការ និងបើសិនជាមានថ្ងៃចេញ ឬថ្ងៃផ្អាកសកម្មភាព
- ទឹកប្រាក់ដុលនៃលាភការ
-ទឹកប្រាក់វាយលំអិតនៃលាភការបន្ទាប់បន្សំម៉ោងបន្ថែម ប្រាក់បំណាច់បុព្វលាភ (ប្រាក់សងម៉ៅការនូវចំណាយ ប្រាក់ឲ្យថែមរោងវង្វាន់ផ្សេងៗ...)
-ប្រភេទនិងទឹកប្រាក់នៃអត្ថប្រយោជន៍ជាវត្ថុបានវាយតម្លៃតាមតម្លៃពិតប្រាកដ
- លាភការរំលឹក
- ប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចី និងប្រាក់រំដោះបានទទួល ឬបានសង
- ប្រាក់កាត់ជាកាតព្វកិច្ចសម្រាប់សង្គមកិច្ច
- មូលដ្ឋានគិតពន្ធ
- ប្រាក់ពន្ធដែលបានកាត់ទុក
-លក្ខណៈនិងទឹកប្រាកនៃលាភការ ប្រភេទនីមួយៗដែលបានចាត់ទុកថាមិនត្រូវជាប់ពន្ធបញ្ជីការគល់បញ្ជើងកសារបើកប្រាក់ប្រគល់ឲ្យអ្នកបម្រើការងារសក្ខីប័ត្រវាយតម្លៃអត្ថប្រយោជន៍ជាវត្ថុប្រាក់សំណងពិតប្រាកដនូវចំណាយ និងរាល់ប្រភេទលាភការឲ្យរួចពន្ធបង្កាន់ដៃបើកប្រាក់ត្រូវរក្សាទុករហូតដល់ផុតឆ្នាំទី៣ បន្ទាប់ពីឆ្នាំដែលបានអនុវត្តការកាត់ទុកនូវប្រាក់ពន្ធ ។

មាត្រា ២២-

ក្នុងករណីដែលពុំបានគោរពបទបញ្ញត្តិទាំងឡាយខាងលើទេនោះទណ្ឌកម្មដែលត្រូវអនុវត្តគឺជាទណ្ឌកម្ម ដែលបានចែងក្នុងមាត្រា ៥៧.៥៩និង៦០ នៃច្បាប់ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ០២ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ។

មាត្រា ២៣-

នីតិវិធីធម្មតានៃការ កំណាត់ឡើងវិញ នូវពន្ធដែលកំណាត់មិនបានត្រឹមត្រូវក្រោយពីការត្រួតពិនិត្យគឺ ជានីតិវិធីដែលបានចែងក្នុងមាត្រា២៤ នៃច្បាប់ដូចមានចែងក្នុងមាត្រាខាងលើ ។

មាត្រា ២៤-

នីតិវិធីនៃការកំណាត់ពន្ធជាឯកតោភាគី របស់រដ្ឋបាលពន្ធដារ ត្រូវអនុវត្តដូចក្នុងករណីបានចែងក្នុងមាត្រា ៥៨ នៃច្បាប់ខាងលើដដែល ។

## II - ពន្ធលើប្រាក់ចំណេញ

មាត្រា ២៥-

១- សហគ្រាសជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិតប្រាកដ មានកាតព្វកិច្ចត្រូវបង់ប្រចាំខែនូវប្រាក់រំដោះពន្ធ លើប្រាក់ចំណេញស្មើនឹង ២% នៃផលរបរ។ ប្រាក់រំដោះនេះនឹងត្រូវបានកាត់ចេញ ពីចំនួនប្រាក់ពន្ធ ដែលត្រូវបង់នាពេលធ្វើការទូទាត់ប្រាក់ពន្ធជាស្ថាពរ ។

២- ក្នុងករណីដែលប្រាក់ពន្ធ លើប្រាក់ចំណេញប្រចាំឆ្នាំ មានចំនួនតិចជាងប្រាក់រំដោះដែលបានបង់ចំនួនលើសនេះ ត្រូវកាត់ចេញពីចំនួនប្រាក់ រំដោះដែលត្រូវបង់សម្រាប់ការិយបរិច្ឆេទក្រោយ ឬត្រូវសងវិញលើកលែងតែប្រាក់រំដោះ 0.៥% លើផលរបរ ដែលជាពន្ធអប្បបរមាលើប្រាក់ចំណេញ ដែលបានបង់នោះមិនអាចកាត់ចេញពីប្រាក់រំដោះប្រចាំខែ សម្រាប់ការិយបរិច្ឆេទបន្ទាប់ឬសងវិញឡើយ ។

## III - ពន្ធលើដីធ្លីមិនបានប្រើប្រាស់

**មាត្រា ២៦-**

ត្រូវបានបង្កើតពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ ដើម្បីជាប្រយោជន៍ថវិកាជាតិ។

**មាត្រា ២៧-**

ពន្ធនេះកំណត់លើដីដែលគ្មាន សំណង់និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានានិងក្នុងតំបន់ទាំងឡាយដែលកំណត់ ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

**មាត្រា ២៨-**

ត្រូវបានបង្កើតគណៈកម្មការមួយហៅថា គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ដែលមានសមាសភាពកំណត់ដោយអនុក្រឹត្យ ។

គណៈកម្មការនេះមានភារកិច្ច ៖

- បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុង ១ ម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ

**មាត្រា ២៩-**

ពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ ត្រូវបង់ដោយកម្មសិទ្ធិករ។

**មាត្រា ៣០-**

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារតាមទីក្រុងនិងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ខែ មិថុនានៃឆ្នាំប្រមូលពន្ធ ។ ក្នុងការគិតពន្ធត្រូវបានអនុញ្ញាតឲ្យកាត់ពីមូលដ្ឋានកំណត់ពន្ធចំនួន ១.២០០ម៉ែក្រក្រឡា ក្នុងដីមួយកន្លែង ។

មាត្រា ៣១-

ពន្ធនេះត្រូវកំណត់តាមអត្រា ២% លើមូលដ្ឋានកំណត់ពន្ធដែលបាន ចែង ក្នុងមាត្រា ៣០ ។

មាត្រា ៣២-

កម្មសិទ្ធិករនៃដីធ្លីជាប់ពន្ធមានភារកិច្ច ត្រូវគណនាប្រាក់ពន្ធ តាមគំរូលិខិតប្រកាសផ្តល់ដោយអង្គការពន្ធ និងត្រូវបង់ពន្ធ នេះយ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ ធ្នូ នៃឆ្នាំនីមួយៗ ជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធស្ថិតនៅ ។ ដីធ្លីជាប់ពន្ធ នីមួយៗ ត្រូវធ្វើលិខិតប្រកាស ១ ច្បាប់ ។

មាត្រា ៣៣-

ការត្រួតពិនិត្យមូលដ្ឋានកំណត់ពន្ធនិងការត្រួតពិនិត្យការបង់ពន្ធ គឺជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៣៤-

ក្នុងករណីដែលពុំបានគោរពបទបញ្ញត្តិនៃមាត្រា ៣៣ទណ្ឌកម្មដែលអនុវត្តគឺជាទណ្ឌកម្មដែលបានចែងក្នុងមាត្រា ៥៧.៥៩ និង៦០ នៃច្បាប់ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

មាត្រា ៣៥-

នីតិវិធីធម្មតានៃការកំណត់ឡើងវិញនូវពន្ធដែលកំណត់មិនបានត្រឹមត្រូវ ក្រោយពីការត្រួតពិនិត្យគឺជានីតិវិធីដែលបានចែងក្នុងមាត្រា ២៨ នៃច្បាប់ដូចមានចែង ក្នុងមាត្រាខាងលើ ។

មាត្រា ៣៦-

នីតិវិធីនៃការកំណត់ពន្ធ ជាឯកតោភាគីរបស់អង្គការពន្ធដារ ត្រូវអនុវត្តធ្វើក្នុងករណីបានចែងក្នុងមាត្រា ៥៨ នៃច្បាប់ខាងលើដដែល ។

## V- អាករលើផលរបរ

**មាត្រា ៣៧-**

អត្រាអាករលើផលរបរត្រូវកំណត់ ១០% ចំពោះ ៖

១- ផលរបរបានមកពីប្រតិបត្តិការជួលធ្វើឡើងក្នុងសណ្ឋាគារ និងសេវាជាឧបសម្ព័ន្ធទាំងឡាយដែលទាក់ទងផ្ទាល់ទៅនឹងសណ្ឋាគារ ។

២- ផលរបរបានមកពីការជួលបន្ទប់លំនៅបំពាក់ដោយចលនវត្ថុធ្វើឡើងដែលមានលក្ខណៈជាវិជ្ជាជីវៈ ។

៣- ផលរបរសម្រេចបាននៅក្នុងគ្រឹះស្ថាន ម៉ាស្សា វង្គសាល និងទីលំហែកំសាន្តនានា ។

៤- ផលរបរសម្រេចបាននៅក្នុងភោជនីយដ្ឋាននិងភេសជ្ជដ្ឋាន ។

**មាត្រា ៣៨-**

ច្បាប់ស្ដីពីការបង្កើតអាករស្នាក់នៅ ដែលបានប្រកាសឲ្យប្រើដោយក្រឹត្យលេខ ៤៤ ក្រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩២ ត្រូវទុកជានិរាករណ៍ ។

## V - ពន្ធប៉ាតង់

**មាត្រា ៣៩-**

ចំនួនប្រាក់ពន្ធប៉ាតង់ដែលបានកំណត់ទុកក្នុងក្រឹត្យច្បាប់លេខ ៦២ ក្រ.ច ចុះថ្ងៃទី១៨ខែមិថុនា ឆ្នាំ១៩៨៥ ត្រូវបានកែប្រែនិងជំនួសដោយចំនួនប្រាក់ពន្ធដូចមានចែងក្នុងតារាងខាងក្រោម ៖

| ថ្នាក់ប៉ាតង់ | ផលរបរប្រចាំឆ្នាំ | | |
|---|---|---|---|
| | សកម្មភាពពាណិជ្ជកម្មឧស្សាហកម្ម | សកម្មភាពសេវាកម្មលើកលែងតែផ្នែកហូបចុកនិងសណ្ឋាគារ | ចំនួនប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំ |
| ១ | ដល់ ៧.៥០០.០០០ ៛ | ដល់ ៣.០០០.០០០៛ | ១៥.០០០៛ |
| ២ | ពី ៧.៥០០.០០១៛ -១២.៥០០.០០០៛ | ពី ៣.០០០.០០១-៥.០០០.០០០៛ | ២១.០០០៛ |
| ៣ | ពី ១២.៥០០.០០១- ២៥.០០០.០០០៛ | ពី ៥.០០០.០០១-១០.០០០.០០០៛ | ២៧.០០០៛ |
| ៤ | ពី ២៥.០០០.០០១- ៣០.០០០.០០០៛ | ពី ១០.០០០.០០១-១២.០០០.០០០៛ | ៤០.០០០៛ |
| ៥ | ពី ៣០.០០០.០០១- ៣៧.៥០០.០០០៛ | ពី ១២.០០០.០០១-១៥.០០០.០០០៛ | ៦០.០០០៛ |
| ៦ | ពី ៣៧.៥០០.០០១- ៥០.០០០.០០០៛ | ពី ១៥.០០០.០០១-២០.០០០.០០០៛ | ៩០.០០០៛ |
| ៧ | ពី ៥០.០០០.០០១-៦២.០០០.០០០៛ | ពី២០.០០០.០០១-២៤.៤០០.០០០៛ | ១៤០.០០០៛ |
| ៨ | ពី ៦២.០០០.០០១-៧៥.០០០.០០០៛ | ពី២៤.៤០០.០០១- ៣០.០០០.០០០៛ | ១៨០.០០០៛ |
| ៩ | ពី ៧៥.០០០.០០១-១០០.០០០.០០០៛ | ពី ៣០.០០០.០០១-៤០.០០០.០០០៛ | ២៤០.០០០៛ |
| ១០ | ពី១០០.០០០.០០១-១០០០.០០០.០០០៛ ជាអតិបរិមាត្រូវបង់បន្ថែម ១ ភាគពាន់ | ពី៤០.០០០.០០១-៤០០.០០០.០០០៛ ជាអតិបរិមាត្រូវបង់បន្ថែម ២.៥ ភាគពាន់ | |

## VI - ពន្ធប្រថាប់ត្រា

មាត្រា ៥០-

១- ពន្ធប្រថាប់ត្រា ត្រូវកំណត់តាមអត្រាសមាមាត្រ ៤% ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬការផ្ទេរសិទ្ធិកាន់កាប់ដី ដែលគ្មានសំណង់ក្រោមរូបភាពជា ការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគទុនក្នុងក្រុមហ៊ុន ។

២- ត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រាសមាមាត្រ ៤% ចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូននិងយានជំនិះដូចខាងក្រោម ៖

- រថយន្តដឹកទំនិញធុនធ្ងន់ រថយន្តដឹកទំនិញធុនស្រាល រថយន្តទោចក្រយានយន្ត
- កាណូត សាឡាង កប៉ាល់

៣- លិខិតមានលក្ខណៈគតិយុត្តិដូចខាងក្រោម ត្រូវជាប់ពន្ធ ប្រថាប់ត្រា ៖

- លិខិតស្តីពីការបង្កើតក្រុមហ៊ុន ១០០.០០០រៀល
- លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ១០០.០០០រៀល
- លិខិតស្តីពីការរំសាយក្រុមហ៊ុន ១០០.០០០រៀល
- កិច្ចសន្យាផ្គត់ផ្គង់សេវាឬសំភារៈទំនិញដល់អង្គការសាធារណៈ ១០០.០០០រៀល

មាត្រា ៥១-

ពន្ធប្រថាប់ត្រាត្រូវបានបង់ ដោយអ្នកទទួលកម្មសិទ្ធិទទួលសិទ្ធិ កាន់កាប់ដីធ្លីដែលគ្មានសំណង់ គិតជាសមាមាត្រលើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់។ ប៉ុន្តែដើម្បីឲ្យមានភាពងាយស្រួលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការគិតគូរប្រាក់ពន្ធដែលត្រូវបង់ ។

មាត្រា ៥២-

ប្រតិបត្តិការទាំងឡាយស្តីពីការផ្ទេរកម្មសិទ្ធិផ្ទេរសិទ្ធិកាន់កាប់និងលិខិតមាន

លក្ខណៈគតិយុត្តិដែលជាប់ពន្ធប្រថាប់ត្រា ត្រូវប្រថាប់ត្រាក្នុងកំលុងពេល ៣ ខែ ចាប់ពីថ្ងៃដែលប្រតិបត្តិការកើតឡើង ។ ហួសរយៈពេលនេះត្រូវពិន័យស្មើនិងចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់ ។

មាត្រា ៤៣-

ហាមភ្នាក់ងារអាជ្ញាធរមានសមត្ថកិច្ចផ្តល់វិញ្ញាបនប័ត្រថ្មីសំគាល់កម្មសិទ្ធិឬសិទ្ធិកាន់កាប់បើម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ថ្មីនោះមិនបានបង់ពន្ធប្រថាប់ត្រា ។

មាត្រា ៤៤-

បែបបទអនុវត្តបញ្ញត្តិទាំងឡាយដែលចែងអំពីពន្ធប្រថាប់ត្រាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៥-

ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រាដែលបានប្រកាសឲ្យប្រើដោយក្រឹត្យលេខ ២១ក្រចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ត្រូវបានកែប្រែដោយបទបញ្ញត្តិទាំងឡាយនៃផ្នែកនេះ ។

## VII - ពន្ធតែមប្រ៊ី

មាត្រា ៤៦-

ពន្ធតែមប្រ៊ី កំណត់លើលិខិតរដ្ឋបាល លិខិតតុលាការលិខិតក្រៅតុលាការនិងលើប័ណ្ណប្រកាស។រាជរដ្ឋាភិបាលកំណត់ដែនអនុវត្ត និងតារាងពន្ធតែមប្រ៊ីដោយអនុក្រឹត្យ ។ ហាមភ្នាក់ងារអាជ្ញាធរមាសមត្ថកិច្ចទទួល ឬចេញលិខិតត្រូវជាប់ ពន្ធតែមប្រ៊ីដែលមិនទាន់បានបង់ពន្ធ ។

មាត្រា ៤៧-

ពន្ធតែមប្រ៊ី ត្រូវបង់តាមការបិទសន្លឹកតែមប្រ៊ី ឬតាមការបង់ប្រាក់ផ្ទាល់ដោយចេញបង្កាន់ដៃ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់បែបបទ និងលក្ខខណ្ឌ អនុវត្តការប្រមូលពន្ធតែមប្រ៊ី ដោយប្រកាស ។

មាត្រា ៤៨-

សន្លឹកតែមប្រើ នីមួយៗមានតម្លៃ ១០០រៀល ២០០រៀល ៥០០រៀល ១០០០ រៀល ២០០០ រៀល ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអង្គការមានសមត្ថកិច្ចតែមួយគត់ក្នុងការធ្វើការបោះពុម្ពសន្លឹកតែមប្រើ ។

មាត្រា ៤៩-

ច្បាប់ស្តីពីការបង្កើតតែមប្រើ សារពើពន្ធ ដែលបានប្រកាសឲ្យប្រើដោយក្រឹត្យលេខ២៣ក្រចុះថ្ងៃទី១៥ខែកុម្ភៈ ឆ្នាំ១៩៩១ត្រូវបានកែប្រែដោយបទបញ្ញត្តិនៃផ្នែកនេះ ។

## ផ្នែកទី ២

## បទបញ្ញត្តិស្តីពី សកម្មភាពត្រួតពិនិត្យ ការប្រមូលចំណូល និងបណ្តឹង

### I- អត្តសញ្ញាណកម្មសហគ្រាស ដែលជាប់ពន្ធតាមរបបពិតប្រាកដ

មាត្រា ៥០-

សហគ្រាសជាប់ពន្ធតាមរបបពិតប្រាកដ ដែលត្រូវកាន់បញ្ជីគណនេយ្យតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជាត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារនិងត្រូវបានអង្គការនេះផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធតែមួយគត់ និងមានលក្ខណៈជាអចិន្ត្រៃយ៍ មិនប្រែប្រួលរហូតដល់ពេលសហគ្រាសឈប់ធ្វើជាសកម្មភាពជាស្ថាពរ ។

មាត្រា ៥១-

លេខអត្តសញ្ញាណកម្មសារពើពន្ធ ដែលនាយកដ្ឋានពន្ធដារ បានផ្តល់ឲ្យនេះ គឺជាលេខសំគាល់តែមួយគត់របស់ សហគ្រាសទោះបីសហគ្រាសមានគ្រឹះស្ថានអាជីវ

កម្មដោយឡែកៗច្រើនក៏ដោយ។ លេខនេះត្រូវប្រើប្រាស់ដោយគ្រប់នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នាយកដ្ឋានពន្ធដារ គឺជាអង្គការមានសមត្ថកិច្ចតែមួយគត់ក្នុងការផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ និងជាអ្នកបញ្ជូនលេខនេះទៅផ្នែកទាំងឡាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៥២-

សហគ្រាសទាំងឡាយដែលបានទទួលលេខអត្តសញ្ញាណកម្ម សារពើពន្ធមានកាតព្វកិច្ចត្រូវចុះ លេខអត្តសញ្ញាណកម្មនេះនៅលើឯកសាររដ្ឋបាលគ្រប់ប្រភេទដូចជាប្រកាសសារពើពន្ធ ប្រតិវេទន៍គយ ព្រមទាំងឯកសារគ្រប់ប្រភេទ ដែលមានលក្ខណៈពាណិជ្ជកម្មដូចជា វិក័យប័ត្រ វិក័យប័ត្រជាទម្រង់ បញ្ជីប៉ាន់តម្លៃពាក្យសុំដេញថ្លៃផ្គត់ផ្គង់សេវា ឬសម្ភារៈទំនិញដល់អង្គការសាធារណៈ ។

មាត្រា ៥៣-

១- សហគ្រាសដែលជាប់ពន្ធតាមរបបពិតប្រាកដ មានភារកិច្ចត្រូវបង្កើត និងប្រើប្រាស់វិក័យប័ត្រ ។

២- រាល់វិក័បត្រដែលពុំមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាសដែលជាអ្នកចេញវិក័យប័ត្រមិនត្រូវបានអនុញ្ញាតឲ្យយកមកគិតគូរសម្រាប់កំណត់លទ្ធផលសារពើពន្ធរបស់សហគ្រាសដែលជាអ្នកទទួលវិក័យប័ត្រហើយនិងជាអ្នកដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញឡើយ ។

## II- សហគ្រាសដែលជាប់អាករលើផលរបរតាមរបបម៉ៅការ

មាត្រា ៥៤-

សហគ្រាសជាប់អាករលើរបបម៉ៅការ ដែលមានផលរបរជាប់ពន្ធក្នុងឆ្នាំ១៩៩៤ តាមបញ្ជីពន្ធរបស់អង្គការពន្ធ មានចំនួនលើសពី១០.០០០.០០០រៀលមានកាតព្វកិច្ចដូចតទៅ ៖

១-ត្រូវកាន់បញ្ជីចំណូលភ្ជាប់ដោយវិក័យប័ត្រ ដើម្បីកំណត់ផលរបររបស់ខ្លួន។គ្រប់ទំព័រនៃបញ្ជី ចំណូលត្រូវតែមានចុះលេខ និង ចុះហត្ថលេខាបញ្ជាក់ជាមុនដោយអង្គការពន្ធ ។ បញ្ជីនេះត្រូវកត់ត្រាគ្រប់ប្រតិបត្តិការដែលសម្រេចបានប្រចាំថ្ងៃនីមួយៗ។ ប៉ុន្តែរាល់ប្រតិបត្តិការ ដែលបានទទួលសាច់ប្រាក់ដល់ដៃដែលមានតម្លៃក្រោម១០០.០០០រៀល បានមកពីការលក់រាយ ឬផ្គត់ផ្គង់សេវាឲ្យអតិថិជនឯកជនអាចអនុញ្ញាតឲ្យចុះបញ្ជីជាសរុបនៅពេលចុងថ្ងៃនីមួយៗ ។

២- សហគ្រាសដែលមានសកម្មភាពលក់ទំនិញក្នុងសភាពដើម ឬផលិតផលដែលផលិតបានត្រូវកាន់បន្ថែមនូវបញ្ជីកត់ត្រាការទិញ ភ្ជាប់ដោយវិក័យប័ត្រនិងសក្ខីបត្រនានា។

៣- ត្រូវបង្ហាញបញ្ជីនិងសក្ខីបត្រនានាដល់អង្គការពន្ធនូវរាល់ពេលដែលអង្គការនេះស្នើសុំ។បើមិនបង្ហាញទេនោះ អ្នកប្រព្រឹត្តល្មើសនឹងត្រូវរងការកំណត់ពន្ធជាឯកតោភាគី ។

## III - ការប្រមូលប្រាក់ពន្ធដែលមិនបានបង់

មាត្រា ៥៥-

ការប្រមូលពន្ធនិងប្រាក់អាករគឺជាសមត្ថកិច្ចរបស់អង្គការពន្ធដែលទទួលបន្ទុកផងដែរក្នុងការកំណត់មូលដ្ឋានជាប់ពន្ធគណនាប្រាក់ពន្ធ និងត្រួតពិនិត្យពន្ធនិងអាករ ។

មាត្រា ៥៦-

ប្រាក់ពន្ធ និងប្រាក់អាករដែលត្រូវបង់ព្រមទាំងប្រាក់ពិន័យដែលបានអនុវត្តបង្កើតបានជាតារាងស្ថានភាពប្រមូលពន្ធសម្រាប់ផ្តល់ជូនទៅផ្នែកទារបំណុលពន្ធនៃអង្គការពន្ធ ។ ប្រាក់ពន្ធដែលបានគិតគូររួចហើយត្រូវទារភ្លាម ។

មាត្រា ៥៧-

បំណុលសារពើពន្ធដែលត្រូវទារគឺជាកម្មវត្ថុនៃលិខិតជូនដំណឹងទារផ្ញើឲ្យអ្នកជំពាក់ប្រាក់ពន្ធដែលអាចជាប្រធានសហគ្រាសឯកត្តជន ឬជានីតិបុគ្គលដែលពាក់ព័ន្ធ ឬជាអ្នកជំពាក់ប្រាក់ពន្ធដទៃទៀតដែលត្រូវបង់ពន្ធឬអាករ ។

មាត្រា ៥៨-

ការមិនបានបង់ប្រាក់ពន្ធប្រាក់អាករ ឬប្រាក់ពិន័យក្នុងកំឡុងពេលមួយខែគិតពីថ្ងៃទទួលលិខិតជូនដំណឹងទារផ្នែកទារបំណុលពន្ធ ត្រូវផ្ញើលិខិតរំលឹកមុនការចាប់ផ្តើមនូវវិធានការតឹងទារ ។ លិខិតរំលឹកនេះផ្តល់រយៈពេលចំនួន ១៥ ថ្ងៃគិតពីថ្ងៃដែលបានទទួលលិខិតជូនដំណឹងដើម្បីទុកឲ្យអ្នកជំពាក់ពន្ធទូទាត់បំណុលសារពើពន្ធ ។ ចំនួនប្រាក់ដែលត្រូវបង់ក្នុងឱកាសរំលឹកនេះ ត្រូវបន្ថែមចំនួន ១០% ជាប្រាក់ពិន័យ ។

មាត្រា ៥៩-

ហួសរយៈពេលរំលឹកខាងលើ ផ្នែកទារបំណុលពន្ធ ត្រូវចាប់ផ្តើមអនុវត្តវិធានការតឹងទារ។ ក្នុងករណីអនុវត្តវិធានការខាងលើ អាជ្ញាធរមូលដ្ឋាននានា និងអង្គការនគរ បាលមានកាតព្វកិច្ចជួយអង្គការពន្ធដារ ក្នុងពេលអង្គការនេះស្នើសុំ ។

មាត្រា ៦០-

វិធានការតឹងទារបំណុលពន្ធមានពីរកម្រិត ៖

កម្រិតទី ១: ការរឹបអូសចលនវត្ថុ ឬអចលនវត្ថុ បិទជាបណ្តោះអាសន្ន ឬជាស្ថាពរនូវគ្រឹះស្ថានវិជ្ជាជីវៈ ដូចជា ឃ្លាំង ភណ្ឌាគារ កន្លែងផលិត ការិយាល័យ រោងជាង ។

កម្រិតទី ២: ការលក់ចលនវត្ថុ ឬ អចលនវត្ថុ ។ អ្នកជាប់ពន្ធអាចប្តឹងជំទាស់ទៅតុលាការរដ្ឋប្បវេណី អំពីការអនុវត្តន៍មិនបានត្រឹមត្រូវ នូវវិធានការតឹងទារនៃផ្នែកទារបំណុលពន្ធ ។

មាត្រា ៦១-

វិធានការតឹងទារត្រូវកត់ត្រាឲ្យច្បាប់ក្នុងកំណត់ហេតុដែលធ្វើឡើងដោយផ្នែកទារបំណុលពន្ធ ។

មាត្រា ៦២-

ការលក់ចលនវត្ថុ ឬអចលនវត្ថុទាំងឡាយអាចអនុវត្តទៅបាន ដរាបណាមានការអនុញ្ញាតពិសេសពីនាយផ្នែកសារពើពន្ធដែលមានសមត្ថកិច្ច តាមសំណើរបស់អ្នកទទួលខុសត្រូវក្នុងការទារបំណុលពន្ធ ។

មាត្រា ៦៣-

ការលក់អាចប្រព្រឹត្តទៅបានក្រោយរយៈពេលមួយខែ គិតចាប់ពីពេលបង្កើតកំណត់ហេតុនៃការអនុវត្តន៍វិធានការតឹងទារកម្រិតទី១។ ការលក់ត្រូវប្រព្រឹត្តតាមបែបបទដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា ៦៤-

ការដាក់ពាក្យសុំដោះស្រាយវិវាទដោយអ្នកជាប់ពន្ធ ឬតតិយជនក្នុងរយៈពេលកំណត់ដែលបានចែងក្នុងមាត្រាខាងលើ សំដៅតវ៉ាឬស្នើបន្ធូរបន្ថយប្រាក់ពន្ធនោះពុំមានឥទ្ធិពលផ្អាកការទារពន្ធនិងផ្អាកការអនុវត្តន៍វិធានការតឹងទារនោះឡើយ ។

មាត្រា ៦៥-

អំពើប្រមាថនឹងអំពើហិង្សាទាំងឡាយ ប្រព្រឹត្តចំពោះភ្នាក់ងារដែលកំពុងអនុវត្តវិធានការតឹងទារ ព្រមទាំងរាល់អំពើប្រឆាំងផ្សេងទៀត គឺជាកម្មវត្ថុនៃការធ្វើកំណត់ហេតុ ។ អ្នកប្រព្រឹត្តអំពើទាំងនេះជាកម្មវត្ថុ នៃបណ្តឹងព្រហ្មទណ្ឌដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## IV -វិធានការផ្សេងៗដែលពាក់ពន្ធដល់ការទារបំណុលពន្ធ

មាត្រា ៦៦-

តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធអាករនឹងពិន័យនៅពេលដែលមានសំណើដោយលិខិតជូនដំណឹងរបស់អង្គការពន្ធ មានភារៈត្រូវបង់ជំនួសអ្នក

ជំពាក់ពន្ធ នូវប្រាក់ពន្ធ ប្រាក់អាករ នឹងប្រាក់ពិន័យដែលអ្នកជំពាក់ពន្ធត្រូវបង់ ដោយប្រើប្រាស់មូលនិធិដែលខ្លួនបានកាន់កាប់នោះ។ នីតិវិធីនៃការជូនដំណឹងចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ត្រូវយកមកអនុវត្តដូចគ្នា ចំពោះតតិយជនដែល ជាកូនបំណុលរបស់អ្នកជំពាក់ពន្ធ ។

មាត្រា ៦៧-

ចាប់តាំងពីពេលបានទទួលលិខិតជូនដំណឹង តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធត្រូវប្រើប្រាស់របស់អ្នកជំពាក់ពន្ធដែលខ្លួនបានកាន់កាប់នោះ សម្រាប់សងជាដាច់ខាតនូវប្រាក់ពន្ធដែលត្រូវបង់ ។

មាត្រា ៦៨-

តតិយជន អ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ដែលមិនបានសងប្រាក់ពន្ធតាមសំណើរបស់ផ្នែកទារ បំណុលពន្ធត្រូវទទួលខុសត្រូវ ដោយខ្លួនឯងក្នុងការយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកបង់ពន្ធ អាករនិងពិន័យដូចគ្នានឹង អ្នកជំពាក់ប្រាក់ពន្ធខាងដើមដែរ ។

មាត្រា ៦៩-

ក្រោយពេលបញ្ជូនលិខិតជូនដំណឹង ចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ប្រសិនបើអ្នកជំពាក់ពន្ធបានសងប្រាក់ពន្ធដែលត្រូវបង់នោះរួចហើយ ផ្នែកទារបំណុលពន្ធត្រូវជូនដំណឹងវិញភ្លាម ស្តីពីមោឃភាពនៃលិខិតជូនដំណឹងដែលខ្លួនបានផ្ញើដល់តតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជំពាក់ពន្ធ ។

មាត្រា ៧០-

អ្នកដែលទទួលមរតកឬអ្នកដែលទទួលអំណោយ មានភារកិច្ចត្រូវសងប្រាក់ពន្ធនិងប្រាក់ពិន័យដែលត្រូវបង់ដោយមរណជន ឬអ្នកផ្តល់អំណោយរហូតដល់គ្រប់ចំនួនទឹកប្រាក់ដែលខ្លួនបានទទួល ។

មាត្រា ៧១-

ក្នុងករណីលក់មូលនិធិពាណិជ្ជកម្ម សហគ្រាស អសង្ហារឹម អ្នកទិញនិងអ្នកលក់ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការសងប្រាក់ពន្ធនិងប្រាក់ពិន័យដែលត្រូវបង់ដោយអ្នកលក់នាពេលលក់ រហូតដល់គ្រប់ចំនួនទឹកប្រាក់ថ្លៃលក់ធម្មតា ។

មាត្រា ៧២-

អ្នកដឹកនាំសហគ្រាស ដែលបានប្រើប្រាស់កលល្បិចបន្លំពន្ធ ឬបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនិងផ្ទួនៗ ចំពោះកាតព្វកិច្ចសារពើពន្ធ នៃសហគ្រាសត្រូវទទួលខុសត្រូវខាងហិរញ្ញវត្ថុក្នុងការសងប្រាក់ពន្ធ និងប្រាក់ពិន័យដែលត្រូវបង់ដោយសហគ្រាស។

មាត្រា ៧៣-

ការបង្ខំលើរូបកាយដើម្បីប្រមូលប្រាក់ពន្ធ ប្រាក់អាករនិងប្រាក់ពិន័យដែលត្រូវបង់ ត្រូវស្នើដោយប្រធានផ្នែកសារពើពន្ធមានសមត្ថកិច្ច ។ ការបង្ខំលើរូបកាយអាចអនុវត្តបានតែក្នុងក្របខ័ណ្ឌ ដែលមានសេចក្តីសម្រេចរបស់តុលាការ ។

## V - អាជ្ញាយុកាលនៃការទារបំណុលពន្ធ

មាត្រា ៧៤-

ការបញ្ញត្តិចេញនូវលិខិតជូនដំណឹងទារបំណុលពន្ធ បញ្ឈប់នូវអាជ្ញាយុកាលដែលកំពុងប្រព្រឹត្តទៅហើយ បើកនូវរយៈពេលអាជ្ញាយុកាលថ្មីមួយទៀតមានចំនួន ៣ ឆ្នាំ។

មាត្រា ៧៥-

១-រយៈពេលនៃអាជ្ញាយុកាលចែងក្នុងមាត្រាខាងលើ ដែលបានកំណត់អំពីការផុតអាជ្ញាយុកាលនៃការទារបំណុលពន្ធ ត្រូវបានពន្យារពេលវេលាដូចគ្នាចំពោះរាល់ការទទួលស្គាល់បំណុលដោយអ្នកជាប់ពន្ធនិងជាប់ពិន័យ ។

២- ក៏ត្រូវពន្យារពេលដូចគ្នាដែរចំពោះវិធានការបញ្ឈប់អាជ្ញាយុកាលទាំងឡាយ

ដែលធ្វើឡើង ដោយអង្គការពន្ធដូចជា ៖ ការបញ្ជូនលិខិតរំលឹក លិខិតជូនដំណឹងចំពោះតតិយជនអ្នកកាន់កាប់ប្រាក់របស់អ្នកជាប់ពន្ធ ឬការអនុវត្តនីតិវិធានការតឹងទារ ។

## VI - អំពីនីតិវិធីនៃការប្រមូលពន្ធ

មាត្រា ៧៦-

១- ការតវ៉ាទាំងឡាយទាក់ទងដល់ការទារបំណុលពន្ធនិងពិន័យ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរផ្ញើមកផ្នែកទារបំណុលពន្ធក្នុងរយៈពេល ២ ខែក្រោយពេលចេញសេចក្តីជូនដំណឹងទារពន្ធ។

២- ការតវ៉ាអាចប្រព្រឹត្តទៅបានចំពោះតែលើ ៖

ក- ការមិនគោរពតាមនីតិវិធីនៃការទារពន្ធដែលបានកំណត់

ខ- ចំនួនទឹកប្រាក់បំណុលសារពើពន្ធរួម ទាំងការទូទាត់ទាំងឡាយដែលបានធ្វើរួចហើយ។

មាត្រា ៧៧-

ការតវ៉ាចំពោះការទារបំណុលពន្ធ អាចធ្វើឡើងដោយអ្នកជាប់ប្រាក់ពន្ធខ្លួនឯងអ្នកតំណាងស្របច្បាប់របស់ខ្លួនឬ ដោយបុគ្គលទាំងឡាយ ដែលមានការកិច្ចទទួលខុសត្រូវរួមគ្នាក្នុងការទូទាត់ប្រាក់ពន្ធ ។

មាត្រា ៧៨-

១- នាយផ្នែកទារបំណុលពន្ធ មានរយៈពេល ២ ខែ គិតពីពេលបានទទួលពាក្យដើម្បីឆ្លើយតបចំពោះបណ្តឹងតវ៉ា

២-ហួសរយៈពេលនេះបើពុំមានសេចក្តីសម្រេចឆ្លើយតបណាមួយ ឬបើមានសេចក្តីសម្រេចឆ្លើយតប ប៉ុន្តែមិនជាទីពេញចិត្តនៃ អ្នកជាប់ប្រាក់ពន្ធអ្នកជាប់ពន្ធមានរយៈពេល ២ ខែ ដើម្បីលើកយកវិវាទនេះប្តឹងទៅតុលាការរដ្ឋប្បវេណី

៣- រយៈពេល ២ខែសម្រាប់ប្តឹងទៅតុលាការត្រូវចាប់ផ្តើម ៖

- ឬមួយពីពេលដែលអង្គការពន្ធបានបញ្ជូនសេចក្តីសម្រេចបដិសេធការតវ៉ា

-ឬមួយចាប់ពីផុតរយៈពេល ២ ខែ ដែលទុកសម្រាប់ឲ្យអង្គការពន្ធដារចេញសេចក្តីសម្រេច ។

## VII - ពន្ធដែលមិនអាចប្រមូលបាន

មាត្រា ៧៩-

១-ផ្នែកទារបំណុលពន្ធអាចស្នើក្នុងរយៈពេល ២ ឆ្នាំ គិតចាប់ពីពេលដែលបានពិនិត្យនិងកត់ត្រាបំណុលពន្ធជាផ្លូវការចាត់ថាជាប្រាក់ពន្ធមិនអាចប្រមូលបាន នូវប្រាក់ពន្ធនិងប្រាក់ពិន័យដែលមិនបានទូទាត់កាលបើការប្រមូលពន្ធ មិនអាចធ្វើបាន ដោយមូលហេតុការបាត់ខ្លួន ឬអសារធនភាពនៃអ្នកជាប់ពន្ធ ។

២-ផ្នែកទារបំណុលពន្ធត្រូវលើកហេតុផលឲ្យបានច្បាស់លាស់ បញ្ជាក់លើសំណើរបស់ខ្លួនអំពីពេលវេលាដ៏សមស្រប និងអំពីវិធានការ ចាំបាច់នានាដើម្បីទទួលនូវការទូទាត់ប្រាក់ពន្ធដែលត្រូវបង់ ។

៣-ការចាត់ជាបំណុល ដែលមិនអាចទារបាន ពុំមានអានុភាពលុបចោលបំណុលសារពើពន្ធរបស់អ្នកជាប់ពន្ធឡើយ ហើយការទារបំណុល ពន្ធអាចអនុវត្តបានគ្រប់ពេល ក្នុងរយៈពេលនៃអាជ្ញាយុកាល ។

មាត្រា ៨០-

សិទ្ធិសម្រេចលើសំណើចាត់ជាប្រាក់ពន្ធមិនអាចទារបាន ជាសមត្ថកិច្ចរបស់ ៖

១- ប្រធាននាយកដ្ឋានពន្ធដារឬតំណាងចំពោះបំណុលពន្ធតិចជាងឬស្មើនឹង ១០.០០០.០០០ រៀល

២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះបំណុលពន្ធលើសពី ១០.០០០.០០០ រៀល ។

## ជំពូកទី ៨

## I-បទបញ្ញត្តិស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

**មាត្រា ៨១-**

នៅក្នុងលក្ខខ័ណ្ឌនិងទៅតាមបែបបទដែលនឹងត្រូវបានកំណត់ដោយអនុក្រឹត្យ រាជរដ្ឋាភិបាលត្រូវបានអនុញ្ញាតឲ្យផ្ទេរទៅផ្នែកឯកជននូវកម្មសិទ្ធិទ្រព្យសកម្មសាធារណៈ ដូចខាងក្រោម ៖

-សហគ្រាសសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម

- ការចូលរួមភាគហ៊ុនសាធារណៈ ក្នុងមូលធននៃក្រុមហ៊ុនសេដ្ឋកិច្ចចំរុះ

- សកម្មភាពសាធារណៈទាំងឡាយដែលមានលក្ខណៈឧស្សាហកម្ម ឬពាណិជ្ជកម្ម

